# សន្លឹកក្រដាសការណ៍ពិត លេខកូដម្ហូប #34

*អ្នកគួរតែដឹងអ្វីខ្លះ អំពីលេខកូដ*

WWW.HEALTHOREGON.ORG/FOODSAFETY

## ការប្រើរថលក់ម្ហូបចល័តជាប់គ្នា

**OAR 333-162-0020, ការតម្រូវទូទៅ**

ថ្វីបើច្បាប់ OAR 333-150-0000 វគ្គ 5-305.11 (D) ព្រមទាំងអនុវគ្គ (a) និង (b) នៃវគ្គនេះក៏ដោយ គង់តែការប្រើ និងបរិក្ខារទាំង អស់ ត្រូវតែផ្ទែកជាប់គ្នានៃរថលក់ម្ហូបចល័ត។

**OAR 333-150-0000, ជំពូក 5-305.11**

**ការតម្រូវប្រព័ន្ធទឹក។**

(C) រថលក់ម្ហូបចល័តទាំងអស់ ត្រូវតែបានរៀប ចំឡើង ដោយមានផ្ទែកជាប់គ្នាអាចចល័តបាន និងមានធុងទឹកសំណល់នៅលើរថ។ រថចល័តអាចនឹងតភ្ជាប់ទៅនឹងទឹក និងលូទឹកស្អុយ បើសិនវាមាននៅឯកន្លែងប្រើការ តែយ៉ាងណាមិញ ធុងទឹកត្រូវតែនៅលើរថ គ្រប់ពេលវេលា ទាំងអស់។ រថលក់ម្ហូបចល័ត មិនអាចនឹងតភ្ជាប់ទៅនឹងប្រព័ន្ធទឹកសាប ដោយគ្មានការ តភ្ជាប់ទៅនឹងប្រព័ន្ធលូទឹកស្អុយ បានយល់ព្រមដែរ។ រថលក់ម្ហូបចល័ត ដែលបានចេញអាជ្ញាប័ណ្ណ មុនថ្ងៃទី 1 ខែកុម្ភៈ 2020 ដែលធុងទឹក និងបំពុងទឹក ជាប់ទាក់ទង ត្រូវបានយកចេញមុនកាលបរិច្ឆេទនោះ គឺមិនបានតម្រូវឲ្យដាក់ប្រព័ន្ធទឹកវិញទេ បើសិនរថគឺបានតភ្ជាប់ទៅនឹងប្រព័ន្ធទឹក និងលូទឹកស្អុយបានយល់ព្រម។ PF

(D) រថលក់ម្ហូបចល័ត ដែលប្រើធុងដាក់ទឹក អាចចល័តបាន និងទឹកសំណល់ ដែលមិន មែនជាប់គ្នាទៅនឹងរថ ត្រូវតែឈប់ប្រើនូវ ធុងទឹកទាំងនេះ ឲ្យទាន់ថ្ងៃទី 1 ខែមករា 2023។ PF

**មូលហេតុសុខភាពសាធារណៈ៖**

មានឧបសគ្គនៅទូទាំងរដ្ឋ ជាមួយវត្ថុមិនជាប់គ្នា នៅស្មៀមលើដីជុំវិញរថចល័ត បង្កើតឲ្យមានកន្លែងជាជំរកសត្វល្អិត និងសត្វកកេរ។ បរិក្ខារមិននៅជាប់រថ អាចបង្កើនហានិភ័យនៃការប្រឡាក់ និងសីតុណ្ហភាពធ្វើឲ្យខូចម្ហូប។

លើសពីនេះទៀត ធុងទឹកមិនជាប់រថ បានក្លាយជា បញ្ហាសុខភាពសាធារណៈ ដោយមានការកំពប់ ទឹកសំណល់ និងការចាក់ទឹកចោលមិនត្រឹមត្រូវ នៅលើកន្លែង ធ្វើឲ្យមានប្រឡាក់លូបង្ហូរទឹក ភ្លៀង និងធ្វើឲ្យបឹង និងស្ទឹងកខ្វក់។

រដ្ឋ Oregon គឺប្លែកពីគេ ថារថលក់ម្ហូបចល័ត អាចនឹងបានអនុញ្ញាតឲ្យប្រើដោយគ្មានហាង ទំនិញ បើសិនក្រសួងសុខភាពមូលដ្ឋាន យល់ព្រម។ ហាងទំនិញ គឺជាចង្ក្រានបាយ មានអាជ្ញាប័ណ្ណ សរាប់ការលាងចាន ទុកដាក់ ម្ហូប និងការចំអិនម្ហូប។ បើសិនអ្នកប្រើ អាចបង្ហាញថាគេអាចធ្វើការនេះទាំងអស់ដោយ សុវត្ថិភាព នៅក្នុងរថលក់ម្ហូបចល័តរបស់គេ នោះគេត្រូវបានអនុញ្ញាតឲ្យប្រើដោយគ្មាន ហាងទំនិញមានអាជ្ញាបណ្ណ។ អ្នកប្រើត្រូវតែរក្សាទុកអ្វីៗដែលត្រូវការ គឺបានដាក់ភ្ជាប់ ឬនៅខាងក្នុងរថ។

**“ជាប់គ្នា” មានន័យថាអ្វីៗជាប់ទាក់ទងគ្នា ជាមួយរថលក់ម្ហូបចល័ត ត្រូវតែបានដាក់ភ្ជាប់ នឹងរូបកាយ និងជាប់លាប់។ ហៅអ្នកត្រួតពិនិត្យ សុខភាពតាមមូលដ្ឋាន មុននឹងដាក់ភ្ជាប់ ឬ ទុកអ្វីៗនៅខាងក្រៅរថរបស់អ្នក។**

ឧទាហរណ៍នៃវត្ថុ**មិន**អនុញ្ញាត មិនជាប់នឹងរថ គឺទូទឹកកក ទូបង្អក ធុងទឹក/ទឹកសំណល់។

ទាំងអស់នេះមិនដែលបានអនុញ្ញាត នៅក្នុងរដ្ឋ Oregon ឡើយ ប៉ុន្តែការបំពានទាំងនេះ នៅ ឥឡូវនេះគឺជាភាពចំបងខ្ពស់ជាងគេ។ យ៉ាងនេះ ធ្វើឲ្យអ្នកត្រួតពិនិត្យ មានសមត្ថភាពបង្ខំឲ្យគេប្រព្រឹត្តតាម។

ការលើកលែងតែរថចល័តថ្នាក់ទី 4 ប៉ុណ្ណោះ អាចនឹងជាឧបករណ៍ដាំស្ល**មួយ** មិនជាប់រថ។ មើល សន្លឹកក្រដាសការណ៍ពិត 20# សំរាប់ ព័ត៌មានថែមទៀត។

ឧទាហរណ៍ដែលល្អ ពីព្រោះអ្វីៗទាំងអស់ គឺនៅខាងក្នុង ឬបានដាក់ភ្ជាប់ទៅនឹងរថ៖







ឧទាហរណ៍ដែល**មិន**ល្អ ពីព្រោះវាមានវត្ថុ នៅខាងក្រៅ៖







Oregon Health Authority